**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តតាកែវ**

**គណៈកម្មាធិការលទ្ធកម្ម**

លេខៈ ............/ ២០១៧ សជណ-លកតក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការងារជួសជុលកែលម្អសួនច្បារចំនួន០២កន្លែង មានផ្ទៃក្រឡាសរុប៩.១១៥ម៉ែត្រការ៉េ (ស្ថិតក្នុងក្រុងដូនកែវ) ជូនរដ្ឋបាលខេត្តតាកែវ

**រដ្ឋបាលខេត្តតាកែវ** សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/ សហគ្រាស( គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា÷ **រដ្ឋបាលខេត្តតាកែវ** នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការស្តីពីការងារជួសជុលកែលម្អសួនច្បារចំនួន០២កន្លែង មានទំហំ៩.១១៥ម៉ែត្រការ៉េ÷សួនច្បារមុខមហោស្រពខេត្តជាប់មាត់បឹងតាកែវ ទំហំ៨.៩៧៥ម៉ែត្រការ៉េ និងសួនច្បាររង្វង់មូលខាងកើតវិមានឯករាជ្យ ទំហំ១៤០ម៉ែត្រការ៉េ (ស្ថិតក្នុងក្រុងដូនកែវ) **ជូនរដ្ឋបាលខេត្តតាកែវ**។

**រដ្ឋបាលខេត្តតាកែវ** បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/ សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្ត ដែលមានអាសយដ្ឋានស្ថិតនៅក្នុងសាលាខេត្តតាកែវ(ភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ)ចាប់ពីថ្ងៃទី..០១..ខែ..វិច្ឆិកា..ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខៈ០៣២៩៣១ ២៧៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី....៣០... ខែ..វិច្ឆិកា.....ឆ្នាំ២០១៧ វេលាម៉ោង..០៨:០០...... ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង..០៨:០០... ថ្ងៃទី ....៣០..... ខែ ....វិច្ឆិកា......... ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មខេត្តតាកែវ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

បានពិនិត្យត្រឹមត្រូវ
អង្គភាពគ្រប់គ្រងលទ្ធកម្មសាធារណៈ

ធ្វើនៅខេត្តតាកែវ ថ្ងៃទី...២០.... ខែ..តុលា......... ឆ្នាំ ២០១៧

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឡាយ វណ្ណៈ**

**ចម្លងជូន**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ការិយាល័យលទ្ធកម្ម)
- ឯកសារ-កាលប្បវត្តិ